CALIFORNIA'S LOW COST AUTO INSURANCE

# សំណួរដែលគេសួរជាញឹកញាប់

| សំណួរ | ចម្លើយ |
|---|---|

**1** តើត្រូវមានលក្ខខណ្ឌតម្រូវអ្វីខ្លះដើម្បីមានសិទ្ធិទទួលបានកម្មវិធីធានារ៉ាប់រងប្រភេទនេះ ?

**ដើម្បីមានសិទ្ធិទទួលកម្មវិធីធានារ៉ាប់រងរថយន្តតម្លៃទាបរបស់រដ្ឋ California ដែលហៅកាត់ថា CLCA អតិថិជនចាំបាច់ត្រូវ៖**
- មានអាជ្ញាប័ណ្ណបើកបររបស់រដ្ឋ California ដែលមានសុពលភាព
- មានរថយន្តតម្លៃ $25,000 ឬ តម្លៃតិចជាងនេះ
- បំពេញតាមគោលការណ៍ណែនាំនៃសិទ្ធិទទួលការធានារ៉ាប់រងតាមកម្រិតប្រាក់ចំណូល
- មានអាយុយ៉ាងតិច 16 ឆ្នាំ

**2** តើលក្ខខណ្ឌតម្រូវនៃប្រាក់ចំណូលមានអ្វីខ្លះ ?

**តទៅនេះជាក្រមិតប្រាក់ចំណូលអតិបរមា តាមទំហំគ្រួសារ ដើម្បីមានសិទ្ធិចូលរួម៖**
- 01 នាក់ - $30,350
- 02នាក់ - $41,150
- 03នាក់ - $51,950
- 04នាក់ - $62,750

"គ្រួសារ" សំដៅដល់សមាជិកទាំងអស់ដែលបានចុះបញ្ជីនៅក្នុងទម្រង់បែបបទពន្ធលើប្រាក់ចំណូលរបស់សហព័ន្ធ ឬ រដ្ឋ។

**3** តើខ្ញុំត្រូវការបញ្ជាក់អំពីប្រាក់ចំណូលរបស់ខ្ញុំដើម្បីដាក់ពាក្យសុំដែរឬទេ ?

**ត្រូវការ។ កម្មវិធីធានារ៉ាប់រងនេះនឹងទទួលយកតែឯកសារណាមួយដូចខាងក្រោមទុកជាភស្តុតាងនៃប្រាក់ចំណូលរបស់គ្រួសារ៖**

| ឈ្មោះកម្មវិធី | ឯកសារចាំបាច់ |
|---|---|
| CalFresh ( បណ្ណជំនួយម្ហូបអាហារ ) | ប័ណ្ណ EBT |
| CalWorks | លិខិតជូនដំណឹង |
| California LifeLine | វិក្កយបត្រដែលបង្ហាញការបញ្ចុះតម្លៃពីក្រុមហ៊ុនទូរស័ព្ទ |
| ជំនួយថាមពលសម្រាប់គ្រួសារដែលមានចំណូលទាប ( LIHEAP Low Income Home Energy Assistance ) | វិក្កយបត្រដែលបង្ហាញការបញ្ចុះតម្លៃពីក្រុមហ៊ុនសេវាទឹកភ្លើង |
| Medi-Cal / Medicaid | ប័ណ្ណកម្មវិធី |
| នាយកដ្ឋានអភិវឌ្ឍការងាររដ្ឋ California [California Employment Development Department ( EDD )] | ប័ណ្ណដកប្រាក់ ឬ លិខិតបញ្ជាក់អត្ថប្រយោជន៍ |
| ប្រាក់ចំណូលសន្តិសុខសង្គម ( មនុស្សចាស់ ពិការភ្នែក ពិការរាងកាយ ) | របាយការណ៍ថ្មីៗពីធនាគារជាភស្តុតាងនៃការ ដាក់ប្រាក់បញ្ញើ |
| សន្តិសុខសង្គម ឬ សោធននិវត្តន | លិខិតពីរដ្ឋបាល |
| កម្រិតប្រាក់ចំណូល * | ច្បាប់ចម្លងនៃប្រតិវេទន៍ពន្ធលើប្រាក់ចំណូលរបស់សហព័ន្ធ ឬ រដ្ឋសម្រាប់ឆ្នាំចុងក្រោយ |
| *លេខសន្តិសុខសង្គម ឬ លេខអត្តសញ្ញាណកម្មអ្នកជាប់ពន្ធដែលគេទទួលយក | ទម្រង់បែបបទ W-2 ឬ ទម្រង់ 1099 |
| | បញ្ជីប្រាក់បៀវត្សរ៍ ឬ លិខិតបញ្ជាក់របស់និយោជក |

**4** តើប័ណ្ណសន្យារ៉ាប់រងរថយន្តតម្លៃទាបរបស់រដ្ឋ **California** ផ្តល់ការធានាអ្វីខ្លះ ?

**កម្មវិធីនេះផ្តល់ជូននូវធានារ៉ាប់រងទទួលខុសត្រូវលើរថយន្តតម្លៃសមរម្យដែលបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់ស្តីពីទំនួលខុសត្រូវហិរញ្ញវត្ថុរបស់រដ្ឋ។**

**កម្រិតនៃទំនួលខុសត្រូវជាមូលដ្ឋានរបស់ប័ណ្ណសន្យារ៉ាប់រងមានដូចតទៅ៖**
- $10,000 ការរងរបួសលើរូបរាងកាយ ឬ ការស្លាប់ក្នុងមនុស្សម្នាក់
- $20,000 ការរងរបួសលើរូបរាងកាយ ឬ ការស្លាប់ក្នុងករណីគ្រោះថ្នាក់មួយលើក
- $3,000 ទំនួលខុសត្រូវលើការខូចខាតទ្រព្យសម្បត្តិក្នុងករណីគ្រោះថ្នាក់មួយលើក

**សម្រាប់ការគិតថ្លៃបន្ថែម $19-$68 ក្នុងមួយឆ្នាំ អតិថិជនអាចបន្ថែម៖**
- $1,000 ថ្លៃសេវាព្យាបាលក្នុងមនុស្សម្នាក់
- $10,000 ការរងរបួសលើរូបរាងកាយនៃអ្នកបើកបរយានយន្តដែលមិនមានការធានារ៉ាប់រង ក្នុងមនុស្សម្នាក់
- $20,000 ការរងរបួសលើរូបរាងកាយនៃអ្នកបើកបរយានយន្តដែលមិនមានការធានារ៉ាប់រង ក្នុងករណីគ្រោះថ្នាក់មួយលើក

*កម្មវិធីនេះមិនផ្តល់ការធានារ៉ាប់រងគ្រប់ជ្រុងជ្រោយ ឬ លើការប៉ះទង្គិច ( ការធានាដែលនឹងធានាដល់ការជួសជុលយានយន្តរបស់អ្នកបើកបរបន្ទាប់ពីជួបហេតុការណ៍គ្រោះថ្នាក់ ) នោះទេ ប៉ុន្តែការធានាប្រភេទនេះអាចរកទិញបានពីភ្នាក់ងារធានារ៉ាប់រង។*

CALIFORNIA'S LOW COST AUTO INSURANCE

# សំណួរដែលគេសួរជាញឹកញាប់

## សំណួរ | ចម្លើយ

**5 តើប័ណ្ណសន្យារ៉ាប់រងកម្មវិធី CLCA មានតម្លៃប៉ុន្មានខ្លះ ?**

បុព្វលាភរ៉ាប់រងប្រចាំឆ្នាំនៅរដ្ឋ **California** គឺខុសៗគ្នាទៅតាមខោនធី នៅចន្លោះចាប់ពី $247 ដល់ $980។ មានការបញ្ចុះតម្លៃជូនអតិថិជនដែលមានប័ណ្ណបើកបររយៈពេល 03 ឆ្នាំ និងមានប្រវត្តិបើកបរល្អ។

ប្រវត្តិបើកបរល្អត្រូវបានកំណត់និយមន័យដូចតទៅ៖

- មិនមានកំហុសបំផ្លាញទ្រព្យសម្បត្តិលើសពីម្តង ឬមិនលើសពីមួយពិន្ទុចំពោះការបំពានលើការបើកបរក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ
- មិនមានកំហុសបង្កគ្រោះថ្នាក់ដែលបណ្តាលឲ្យមានការរងរបួសលើរាងកាយ ឬ ការស្លាប់ ក្នុងប្រវត្តិបើកបររយៈពេលបីឆ្នាំចុងក្រោយ
- មិនធ្លាប់មានការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ បទមជ្ឈឹមចំពោះការបំពានក្រមបើកបរយានយន្តដែលត្រូវបានកត់ត្រានៅក្នុងប្រវត្តិបើកបរយានយន្ត។

ដើម្បីពិនិត្យអត្រាតម្លៃដែលចេញដោយខោនធី ឬដើម្បីគណនាតារាងពេលវេលាបង់ប្រាក់ * សូមចូលទៅកាន់ mylowcostauto.com។

***CLCA** ផ្តល់ជូនជម្រើសបង់ប្រាក់ចំនួនពីរ៖**

- បង់ប្រាក់គ្រប់ចំនួនតែមួយលើក ឬ
- បង់បណ្តាក់ 20% ជា 07 ដំណាក់កាល (សម្រាប់ការបង់ប្រាក់ក្នុងមួយដំណាក់កាលៗ នឹងមានការគិតថ្លៃសេវាប្រតិបត្តិការចំនួន $4.00)

**6 តើអ្នកដាក់ពាក្យសុំកម្មវិធីធានារ៉ាប់រងនេះដោយវិធីណា ?**

**ដើម្បីដាក់ពាក្យសុំកម្មវិធីធានារ៉ាប់រងរថយន្តតម្លៃទាបរបស់រដ្ឋCalifornia សូមអនុវត្តតាមជំហានទាំង** 03 **ដូចខាងក្រោម៖**

1 បំពេញកម្រងសំណួរអំពីសិទ្ធិទទួលបានកម្មវិធីធានារ៉ាប់រង
2រួចហើយ បញ្ចប់ដំណើរការដាក់ពាក្យសុំ
- ឥឡូវ មានតាមអ៊ីនធឺណិត 100% ឬ ជួបជាមួយភ្នាក់ងារក្នុងតំបន់ ដោយឥតគិតថ្លៃ

ដើម្បីចាប់ផ្តើមដាក់ពាក្យសុំនៅពេលឥឡូវនេះ សូមចូលទៅកាន់ mylowcostauto.com ហើយចុចប៊ូតុង Act Now ដើម្បីចាប់ផ្តើម។

ប្រសិនបើអ្នកមិនមានបណ្តាញអ៊ិនធឺណិត ឬ ត្រូវការជំនួយបន្ថែម សូមហៅទូរស័ព្ទទៅកាន់លេខ 1-866-602-8861។

**7 តើការដាក់ពិន័យអ្វីខ្លះ ប្រសិនបើមិនមានធានារ៉ាប់រងរថយន្ត ?**

ប្រសិនបើអ្នកត្រូវបានពិន័យដោយសារពុំមានធានារ៉ាប់រងរថយន្តនៅពេលមានការបំពានលើការបើកបរកើតឡើង ឬ នៅពេលជួបហេតុការណ៍គ្រោះថ្នាក់ វិធានការពិន័យមានដូចជា ប្រាក់ពិន័យ និងលទ្ធភាពនៃការព្យួរការចុះបញ្ជីយានយន្ត។

សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងការដាក់ពិន័យដោយសារពុំមានធានារ៉ាប់រងរថយន្ត សូមចូលទៅកាន់គេហទំព័រ California DMV តាមរយៈ **http://chilp.it/9a5b9c2** (អាសយដ្ឋាននេះនាំនឹងអ្នកដោយផ្ទាល់ទៅមើលផ្នែក VC Section 16029)។

**8 តើរថយន្តចំនួនប៉ុន្មានគ្រឿងដែលអាចទទួលប័ណ្ណសន្យារ៉ាប់រងពីកម្មវិធីធានារ៉ាប់រង CLCA ?**

អតិថិជនដែលត្រូវតាមលក្ខខណ្ឌតម្រូវនៃកម្មវិធីធានារ៉ាប់រងនេះត្រូវបានអនុញ្ញាតឲ្យទទួលប័ណ្ណសន្យារ៉ាប់រងតម្លៃទាបចំនួនដល់ទៅពីរដោយយោងតាមគោលការណ៍ណែនាំនៃកម្មវិធីនេះ។ ប្រសិនបើមានសមាជិកពីរនាក់ក្នុងគ្រួសារដែលត្រូវតាមលក្ខខណ្ឌតម្រូវនៃកម្មវិធីនេះ ម្នាក់ៗអាចទទួលបានប័ណ្ណសន្យារ៉ាប់រងចំនួនពីរ ដែលសរុបទៅគឺមានប័ណ្ណសន្យារ៉ាប់រងដល់ទៅបួនក្នុងមួយគ្រួសារ។

ឧទាហរណ៍ បុគ្គលម្នាក់អាចមានរថយន្តច្រើនបំផុតចំនួនពីរគ្រឿងដែលអាចទទួលកម្មវិធីធានារ៉ាប់រង ហើយគូស្វាមីភរិយាអាចទទួលការធានារ៉ាប់រងសម្រាប់យានយន្តច្រើនបំផុតចំនួន 04 គ្រឿង ប្រសិនបើយានយន្តនីមួយៗត្រូវបានចុះបញ្ជីដោយប្រើឈ្មោះរបស់ពួកគេរៀងៗខ្លួន។

**9 ហេតុអ្វីបានជាយានយន្តទាំងអស់ក្នុងគ្រួសារត្រូវបញ្ចូលទៅក្នុងកម្មវិធី CLCA ?**

កម្មវិធីនេះតម្រូវឲ្យយានយន្តទាំងអស់ក្នុងគ្រួសារទទួលបានការធានារ៉ាប់រងនៅក្នុងកម្មវិធី។ ដូច្នេះ ដើម្បីមានសិទ្ធិទទួលបានការធានារ៉ាប់រងលើយានយន្តមួយគ្រឿងនៅក្នុងកម្មវិធីនេះ អតិថិជនអាចនឹងមិនមានការធានារ៉ាប់រងភារៈទទួលខុសត្រូវតាមរយៈប័ណ្ណសន្យារ៉ាប់រងណាមួយផ្សេងទៀតសម្រាប់យានយន្តផ្សេងទៀតនៅក្នុងគ្រួសារ។

"គ្រួសារ" សំដៅដល់សមាជិកទាំងអស់ដែលបានចុះបញ្ជីនៅក្នុងទម្រង់បែបបទពន្ធលើប្រាក់ចំណូលរបស់សហព័ន្ធ ឬ រដ្ឋ។

**10 តើខ្ញុំអាចទទួលការធានាតាមរយៈប័ណ្ណសន្យារ៉ាប់រង CLCA ដែរឬទេ ប្រសិនបើខ្ញុំមានកម្ចីទិញរថយន្ត ?**

បាទ/ចាសអ្នកអាច ប៉ុន្តែអ្នកគួរពិនិត្យបញ្ជាក់ជាមួយអ្នកផ្តល់កម្ចីឲ្យអ្នកដើម្បីកំណត់ថាតើកម្រិតនៃការធានាដែលផ្តល់ដោយកម្មវិធីនេះ នឹងអាចបំពេញតាមលក្ខខណ្ឌតម្រូវនៃកម្ចីរបស់អ្នកដែរឬទេ។